# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាថ្ងៃសុក្រពិសិដ្ឋនៅចំការឡៀង
# ថ្ងៃទី១៤ មេសា ២០១៧

អត្ថបទទី១៖ អស ៥២,១៣ដល់៥៣,១២
អត្ថបទទី២៖ ហប ៤,១៤-១៦;៥,៧-៩
ដំណឹងល្អ៖ យហ ១៨,១-១៩,៤២

បងប្អូនជាទីស្រឡាញ់!

ពេលព្រះយេស៊ូត្រូវគេឆ្កាង ព្រះអង្គមានព្រះបន្ទូលថា **អេលី អេលី សាបាតានី** មានន័យថា **ឱព្រះបិតាអើយ! មូលហេតុអ្វីព្រះអង្គលះបង់ចោលទូលបង្គំ។** ព្រះយេស៊ូបានធ្វើដំណើរជាមួយក្រុមគ្រីស្តទូតបីឆ្នាំ ព្រះយេស៊ូដែលបានធ្វើដំណើរជាមួយមហាជនដែលស្រឡាញ់ព្រះយេស៊ូណាស់ ព្រោះព្រះអង្គណែនាំឲ្យគេមានជីវិត ណែនាំឲ្យគេមានសេចក្តីសង្ឃឹម ណែនាំឲ្យគេរួចផុតពីអំពើបាបនានា។ គេបានគោរពព្រះយេស៊ូជាព្រះមហាក្សត្ររបស់គេហើយ ជយោព្រះរាជ្យវង្សព្រះបាទដាវីឌ ព្រះយេស៊ូបានមើលឃើញមហាជននេះនៅព្រះអង្គត្រូវគេឆ្កាង ព្រះយេស៊ូមើលឃើញបូជាចារ្យ មើលឃើញទាហាន មើលឃើញមនុស្សយ៉ាងច្រើនដែលកំពុងសម្លឹងមើលព្រះអង្គ និងកំពុងសើចចម្អកដាក់ព្រះអង្គ។ ឱព្រះបិតាអើយមូលហេតុអ្វីបានជាព្រះអង្គលះបង់ចោលទូលបង្គំ ប៉ុន្តែភ្លាមនោះព្រះយេស៊ូមានព្រះបន្ទូលថែមថា **"ឱព្រះបិតាអើយ! សូមលើកលែងទោសឲ្យគេផង ព្រោះគេមិនដឹងថាគេកំពុងធ្វើអ្វីនោះទេ"**។ នៅក្នុងមហាជននេះមានស្ត្រីសាម៉ារី មានលោកសាខេ មានលោកបាទីមេ មានអ្នកជំងឺជាច្រើនដែលព្រះអង្គបានប្រោសឲ្យគេជាសាស្បើយ ក្នុងមហាជននេះក៏មានលោកសិលា មានយ៉ាកុប មានបាតូឡូមេ មានយ៉ូហាន ឱព្រះបិតាអើយសូមលើកលែងទោសឲ្យគេផង ព្រោះគេមិនដឹងថាគេកំពុងធ្វើអ្វីនោះទេ។ ក្នុងចំណោមមហាជននេះ ដែលកំពុងសម្លឹងមើលព្រះយេស៊ូមានខ្ញុំ មានបងប្អូនម្នាក់ៗ ដែលពេលខ្លះបានធ្វើដំណើរជិតស្និតជាមួយព្រះយេស៊ូ។ ជួនកាលយើងបានឆ្លើយដូចលោកសិលាថា ខ្ញុំមិនដែលស្គាល់ព្រះអង្គទេ នៅក្បែរឈើឆ្កាងមាននាងម៉ារីមាតារបស់ព្រះអង្គ មានលោកយ៉ូហានសាវ័កជាទីស្រឡាញ់របស់ព្រះអង្គ។ នៅសល់តែពីរនាក់ដែលកំពុងពិបាកចិត្ត ប៉ុន្តែពេលនោះព្រះយេស៊ូដោយមើលឃើញម្តាយរបស់ព្រះអង្គ ហើយព្រះអង្គមានព្រះបន្ទូលថា **"នាងអើយ! នេះជាកូនរបស់នាង"** និងដោយមើលលោកយ៉ូហាន ព្រះអង្គមានព្រះបន្ទូលថា **"យ៉ូហានអើយ! នេះជាមាតារបស់អ្នក"**។ នៅលើឈើឆ្កាង ព្រះយេស៊ូកំពុងប្រទានម្តាយដ៏ជាទី

ស្រឡាញ់របស់ព្រះអង្គឲ្យយើងទាំងអស់គ្នា នាងម៉ារីទៅជាម្តាយរបស់ខ្ញុំដែលព្រះយេស៊ូប្រទានឲ្យ។ និងសាវ័កជាទីស្រឡាញ់ ដែលប្រហែលជាខ្ញុំនៅពេលនេះ។ នៅក្បែរព្រះយេស៊ូមានចោរព្រៃពីរនាក់ មានម្នាក់ចម្អកដាក់ព្រះយេស៊ូថា សង្គ្រោះខ្លួនឯងទៅ ប៉ុន្តែម្នាក់ទៀតយល់ថា ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា **"ខ្ញុំប្រាប់នៅថ្ងៃនេះ អ្នកនឹងនៅជាមួយខ្ញុំនៅស្ថានបរមសុខ"** ទោះបីខ្ញុំជាអ្នកមានបាបក៏ដោយ បើខ្ញុំទទួលស្គាល់ថាព្រះយេស៊ូជាព្រះបុត្រាជាទីស្រឡាញ់របស់ព្រះបិតា នោះព្រះយេស៊ូនឹងលើកលែងទោសឲ្យខ្ញុំ និងឲ្យខ្ញុំចូលស្ថានបរមសុខជាមួយព្រះអង្គដែរ។

ព្រះយេស៊ូមានព្រះបន្ទូលមួយថែមទៀតថា **"ខ្ញុំស្រេកទឹក"** ព្រះយេស៊ូនៅតែបន្តមានព្រះបន្ទូលដដែលនៅថ្ងៃនេះ ខ្ញុំស្រេកទឹកដើម្បីឲ្យមនុស្សលោកកែប្រែចិត្តគំនិត ស្រេកទឹកដើម្បីឲ្យមនុស្សបំផ្លាញសង្គ្រាម ភាវរកម្ម ស្រេកទឹកដើម្បីឲ្យមនុស្សលោកដើរឆ្ងាយពីភាពអយុត្តិធម៌ ភាពក្រីក្រ ស្រេកទឹកនៅពេលមនុស្សលោក ជិះជាន់កូនក្មេង ជនពិការ និងអ្នកដែលគ្មានតម្លៃសម្រាប់គេ។ ថ្ងៃនេះព្រះយេស៊ូស្រេកទឹក នៅពេលមើលយើង ហើយមានព្រះបន្ទូលឲ្យយើងកែប្រែចិត្តគំនិត និងដើរតាមព្រះអង្គដើម្បីទទួលជីវិតដ៏បរិបូរណ៍។ ព្រះយេស៊ូបានចាប់កំណើតជាមនុស្ស ជាអ្នកក្រីក្របំផុតនៅក្រោលគោក្នុងភូមិបេថ្លេហិម នៅពេលនេះព្រះយេស៊ូសោយទិវង្គត ជាអ្នកក្រីក្រដល់កំពូលគ្មាននៅសល់អ្វីសោះ មហាជនក្បត់គាត់ គ្រីស្តទូតនិងសាវ័កបានរត់ចោលគាត់។ ព្រះយេស៊ូ បានលះបង់ចោលទាំងអស់ នេះជារូបកាយរបស់ខ្ញុំ នេះជាលោហិតរបស់ខ្ញុំ ដើម្បីរំដោះបាបដល់យើងទាំងអស់គ្នា។ បពិត្រព្រះបិតាអើយ នៅពេលនេះខ្ញុំផ្ញើជីវិតនៅក្នុងព្រះហស្តរបស់ព្រះអង្គ និងព្រះយេស៊ូសោយទិវង្គតសម្រាប់យើងនៅថ្ងៃនេះ ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតថ្មីនៅពេលព្រះយេស៊ូឡើងស្ថានបរមសុខ។ យើងនៅស្ងៀមស្ងាត់ ដោយនឹកឃើញម្តងទៀត ព្រះយេស៊ូដែលបានស្រឡាញ់ខ្ញុំរហូតដល់សុខចិត្តបូជាជីវិតនៅលើឈើឆ្កាង។ អាម៉ែន។